ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការនិងសាសនា
លេខ: ១៧/២៤ ក.ធ.សស៥៣

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា

# រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

**យោង៖**-ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- អនុក្រឹត្យលេខ ១៥៤ អនក្រ.បក. ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- ប្រកាសលេខ ១៩/១២ ក.ធ.ស/ប្រ.ក ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការប្រើប្រាស់សៀវភៅកម្មវិធីពុទ្ធិកសិក្សា
- លិខិតលេខ ១៤៣/២៤ អ.ព.ស.ជ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ ស្តីពីផែនការប្រឡងសម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥

ក្រសួងធម្មការនិងសាសនា សូមជូនដំណឹងដល់ លោក លោកស្រី ជាប្រធានមន្ទីរធម្មការនិងសាសនា គ្រប់រាជធានី ខេត្ត ឱ្យបានជ្រាបថា: ក្រសួងនឹងរៀបចំការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា សម្រាប់ដំណាច់ឆ្នាំសិក្សា ២០២៤-២០២៥ តាមលក្ខខណ្ឌដូចខាងក្រោម៖

**១. កាលបរិច្ឆេទនៃការប្រឡង៖**

ថ្ងៃសៅរ៍-អាទិត្យ ៥-៦រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨-១៩ ខែមករា ឆ្នាំ២០២៥។

**២. សំណុំលិខិតដែលបេក្ខសមណៈ បេក្ខជនត្រូវភ្ជាប់មកជាមួយមាន៖**

| | |
|---|---|
| - ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថតទំហំ (៤x៦) | ចំនួន ១ ច្បាប់ |
| - លិខិតបញ្ជាក់ការសិក្សា | ចំនួន ១ ច្បាប់ |
| - សលាកបត្រឯកត្តជនទំហំ (១៥ x ២១) មានបិទរូបថតទំហំ (៤x៦) | ចំនួន ២ ច្បាប់ ⁄. |

- សំបុត្រកំណើត ( ថតចម្លង ) ចំនួន ១ ច្បាប់
- រូបថតទំហំ ( ៤x៦ ) ថតចំពីមុខ (ថតឃ្លុំ) ភ្ជាប់មកជាមួយ ចំនួន ៤ សន្លឹក

### ៣. មុខវិជ្ជាដែលត្រូវប្រឡងមាន៖

| | | | | |
|---|---|---|---|---|
| - ភាសាបាលី | រយៈពេល | ១២០ | នាទី | ពិន្ទុ ៦០ |
| - តែងសេចក្ដី | រយៈពេល | ១២០ | នាទី | ពិន្ទុ ៤០ |
| - ប្រវត្តិ-ភូមិ-វិទ្យាសាស្ត្រអនុវត្តន៍ | រយៈពេល | ១២០ | នាទី | ពិន្ទុ ២០ |
| - ពុទ្ធវិន័យ ពុទ្ធប្បវត្តិ ពុទ្ធសាសនា | រយៈពេល | ១២០ | នាទី | ពិន្ទុ ៦០ |
| - សរសេរតាមអាន | រយៈពេល | ៩០ | នាទី | ពិន្ទុ ៤០ |
| - គណិតវិទ្យា | រយៈពេល | ១២០ | នាទី | ពិន្ទុ ៤០ |

- បន្ថែមទៅលើ (ធ១+ ធ២ ថ្នាក់ទី៣នៃឆ្នាំសិក្សា) ស្មើនឹង ១០០% នៃពិន្ទុសរុប

### ៤. មណ្ឌលប្រឡង៖

**ក. មណ្ឌលរាជធានីភ្នំពេញមាន ២ រាជធានី ខេត្ត**
- រាជធានីភ្នំពេញ ខេត្តកណ្ដាល

**ខ. មណ្ឌលបាត់ដំបងមាន ២ ខេត្ត**
- ខេត្តបាត់ដំបង ខេត្តប៉ៃលិន

**គ. មណ្ឌលកំពង់ចាមមាន ១ ខេត្ត**
- ខេត្តកំពង់ចាម

**ឃ. មណ្ឌលតាកែវមាន ១ ខេត្ត**
- ខេត្តតាកែវ

**ង. មណ្ឌលកំពតមាន ៤ ខេត្ត**
- ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង

**ច. មណ្ឌលព្រៃវែងមាន ១ ខេត្ត**
- ខេត្តព្រៃវែង

**ឆ. មណ្ឌលសៀមរាបមាន ២ ខេត្ត**
- ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ

**ជ. មណ្ឌលកំពង់ឆ្នាំងមាន ១ ខេត្ត**
- ខេត្តកំពង់ឆ្នាំង

**ឈ. មណ្ឌលស្វាយរៀងមាន ១ ខេត្ត**
- ខេត្តស្វាយរៀង

**ញ. មណ្ឌលកំពង់ធំមាន ២ ខេត្ត**
- ខេត្តកំពង់ធំ ខេត្តព្រះវិហារ

**ដ. មណ្ឌលបន្ទាយមានជ័យមាន ១ ខេត្ត**
- ខេត្តបន្ទាយមានជ័យ

**ឋ. មណ្ឌលក្រចេះមាន ៤ ខេត្ត**

- ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី ខេត្តរតនគិរី

**ឌ. មណ្ឌលពោធិ៍សាត់មាន ១ ខេត្ត**

- ខេត្តពោធិ៍សាត់

**ឍ. មណ្ឌលត្បូងឃ្មុំមាន ១ ខេត្ត**

- ខេត្តត្បូងឃ្មុំ

**ណ. មណ្ឌលកំពង់ស្ពឺមាន ១ ខេត្ត**

- ខេត្តកំពង់ស្ពឺ

ក្រសួងធម្មការនិងសាសនា ចាប់ផ្តើមបើកឱ្យទទួលពាក្យសុំចុះឈ្មោះប្រឡង នៅតាមមណ្ឌលប្រឡងទាំង១៥ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ដោយឡែកនៅមណ្ឌលរាជធានីភ្នំពេញ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការនិងសាសនា ជាអ្នករៀបចំការប្រឡង។

លោក លោកស្រី ប្រធានមន្ទីរធម្មការនិងសាសនាខេត្ត ដែលជាប្រធានមណ្ឌលទាំង១៤ ត្រូវធ្វើការផ្សព្វផ្សាយ អំពីការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សានេះ ឱ្យបានជ្រាបដល់បណ្តាវត្តដែលមានបើកសាលាពុទ្ធិកបឋមសិក្សាថ្នាក់ឆ្នាំទី៣ នៅតាមបណ្តាខេត្តជាចំណុះរបស់ខ្លួន។

ម្យ៉ាងទៀត ក្រោយបញ្ចប់ការទទួលពាក្យសុំចុះឈ្មោះប្រឡងបានចប់សព្វគ្រប់ហើយ លោក លោកស្រី ប្រធានមន្ទីរធម្មការនិងសាសនា ត្រូវបញ្ជូនឈ្មោះគណៈកម្មការប្រឡង និងបញ្ជីរាយនាមបេក្ខសមណៈ បេក្ខជន នៅតាមបន្ទប់នីមួយៗ មកកាន់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ (ការិយាល័យពុទ្ធិកបឋមសិក្សា) ដោយមានការរៀបចំគណៈកម្មការគ្រប់ផ្នែក សម្រាប់ដំណើរការប្រឡងក្នុងមណ្ឌលឱ្យបានសមស្របតាមចំនួនបេក្ខសមណៈ បេក្ខជនផង ឱ្យបានមុនថ្ងៃទី៦ **ខែធ្នូ ឆ្នាំ២០២៤** ជាកំហិត។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ចាយ_បូរិន**

**កន្លែងទទួល៖**

- សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
  គណៈសង្ឃនាយកទាំងពីរគណៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជននិងកីឡា
  "ដើម្បីថ្វាយ ជូនជ្រាប"
- រដ្ឋបាលរាជធានី ខេត្ត
- អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត
- គ្រប់អង្គភាពពាក់ព័ន្ធ
  "ដើម្បីសហការអនុវត្ត"

ឯកសារ កាលប្បវត្តិ